សេចក្តីជូនដំណឹង

ការបើកបង្ហូរទឹកពីក្បាលម៉ាស៊ីនទឹកពន្លត់អគ្គីភ័យ និងការបង្វិលទ្វារទឹក នារដូវផ្ការីក

កិច្ចការនេះត្រូវបំពេញ៖ ពីថ្ងៃ ចន្ទ ដល់ថ្ងៃ សុក្រ ពីម៉ោង ៨ព្រឹក ដល់ ២រសៀល (លើកលែងតែមានសេចក្តីជូនដំណឹងផ្សេងពីនេះ)

ផ្នែកផ្គត់ផ្គង់ទឹកក្នុងតំបន់ឡូវែល នឹងបំពេញកិច្ចការបង្វិលទ្វារទឹក និង បង្ហូរទឹកពីក្បាលម៉ាស៊ីនទឹកពន្លត់អគ្គីភ័យប្រចាំឆ្នាំ នៅតំបន់ Pawtucketville នារដូវផ្ការីកនេះ។ សូមបងប្អូនជ្រាបថា នៅក្នុងអំឡុងពេលនៃដំណើរការនេះ បងប្អូនអាចសង្កេតឃើញសម្ពាធទឹកខ្សោយជាងមុន និងទឹកអាចមានប្រែពណ៌ខ្លះផង។

យើងខ្ញុំសូមអភ័យទោស ចំពោះការរំខានណាមួយ ដែលអាចកើតមានឡើងចំពោះបងប្អូនសហគមន៍យើង។ ទោះជាយ៉ាងនេះក្តី នីតិវិធីនៃប្រព័ន្ធថែទាំនេះ ពិតជាមានសារសំខាន់ខ្លាំង ដែលត្រូវអនុវត្តជាប្រចាំរៀងរាល់ឆ្នាំ។ កម្មវិធីនេះ អាចរក្សាគុណភាពទឹក ឲ្យនៅស្អាតល្អ ទ្វារទឹកឲ្យនៅបិទបើកបានស្រួល និងក្បាលម៉ាស៊ីនទឹកពន្លត់អគ្គីភ័យ ត្រូវបានពិនិត្យ ដើម្បីធានាប្រតិបត្តិការត្រឹមត្រូវរបស់វា។

ទោះបីជាទឹកប្រើប្រាស់របស់យើង មានសុវត្ថិភាព ក្នុងការប្រើប្រាស់ក្នុងដំណាក់កាលនេះក្តី ក៏បងប្អូនយើង គួរផ្អាកការបោកគក់ នៅពេលទឹកប្រែពណ៌។ សូមបងប្អូនចៀសវាងបើកទឹកក្តៅ ព្រោះអីវាអាចធ្វើឲ្យម៉ាស៊ីនទឹកក្តៅរបស់បងប្អូនឡើងកំណក។ ក្រោយការបើកបង្ហូរទឹកចេញពីក្បាលម៉ាស៊ីនទឹកពន្លត់អគ្គីភ័យ នៅតំបន់របស់បងប្អូនរួចមក បងប្អូនគ្រប់គ្នាគួរបើកទឹកត្រជាក់ ចោលដាក់ក្នុងអាងងូតទឹក បើអាចធ្វើបាន ឬបើកទឹកត្រជាក់ដាក់ឡាបូលាងចាន រហូតដល់ទឹកនោះឡើងថ្លា មុនចាប់ផ្តើមប្រើប្រាស់វាតាមធម្មតាឡើងវិញ។

សូមបងប្អូនទាក់ទងទៅខាងផ្នែកផ្គត់ផ្គត់ទឹកក្នុងតំបន់ឡូវែល តាមលេខនេះ៖ (978) 674-4242 បើបងប្អូនមានសំណួរ ឬកង្វល់អ្វីមួយ។ បងប្អូនអាចរកព័ត៌មានបន្ថែមទៀត នៅលើគេហទំព័ររបស់យើង៖

https://www.lowellma.gov/645/Water-Utility